៣០
6

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿង រដ្ឋប្បវេណី
លេខ: ៤៧៣
ចុះថ្ងៃទី ១៩-១០-២០១១

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី ២២ខែកុម្ភៈឆ្នាំ២០១៦
វេលាម៉ោង ៨ ʰ ០០ ព្រឹក ។

សាលដីកា
លេខ: ០៦ ក្រ IV "ប"
ចុះថ្ងៃទី ២២-០២-២០១៦

**សមាសភាពក្រុមប្រឹក្សា**

លោក [redacted] ប្រធានក្រុមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់លើសំណុំរឿងរដ្ឋប្បវេណីលេខ ៤៧៣ ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១១ ដែលមាន៖

-ដើមចោទឈ្មោះ [redacted] វ៉ុចស៊ាង ភេទស្រី អាយុ ៤៣ឆ្នាំ ទីលំនៅផ្ទះលេខ ៥៤ AE0-1 ផ្លូវលេខ ២០៤ ក្រុមទី ១៥ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ឪពុកឈ្មោះ [redacted] ឈីវគង់ "ស" ម្ដាយឈ្មោះ [redacted] អេង "ស" ប្ដីឈ្មោះ [redacted] សុភាណ មានកូន ០៣នាក់ ។

-មេធាវី: [redacted]

-ចុងចម្លើយឈ្មោះ [redacted] សុភាណ ភេទប្រុស អាយុ ៤៣ឆ្នាំទីលំនៅផ្ទះលេខ៥៤AE0-1 ផ្លូវលេខ២០៤ ក្រុមទី១៥ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ។ ឪពុកឈ្មោះ [redacted] តាយ "រ" ម្ដាយឈ្មោះ [redacted] ចេងលន "រ" ប្រពន្ធឈ្មោះ [redacted] វ៉ុចស៊ាង មានកូន ០៣នាក់។

-មេធាវី: [redacted]

**កម្មវត្ថុបណ្ដឹង**

-ដើមចោទឈ្មោះ [redacted] វ៉ុចស៊ាង ប្ដឹងសុំលែងលះប់រស់នៅជា អនីតិសង្វាស ពីចុងចម្លើយឈ្មោះ

៣៦១



Scanned with CamScanner

[redacted] សុភា ណា , សុំសិទ្ធិគ្រប់គ្រងកូន និងអាហារកិច្ចចិញ្ចឹមកូន , សុំបែងចែកទ្រព្យរួម ។

**អង្គហេតុ និង ចំណុចវិវាទ:**

-តាមពាក្យបណ្តឹងរបស់ឈ្មោះ [redacted] វួចស៊ាង ចុះថ្ងៃទី ០១/០២/២០១១ ប្តឹងសុំឲ្យតុលាការចេញសាលក្រមតាមការទាមទារដូចខាងក្រោម:

១/ឲ្យឈ្មោះ [redacted] វួចស៊ាង ឈប់រស់នៅជាអនីតិសង្វាស់ជាមួយឈ្មោះ [redacted] សុភាណ ។

២/ប្រគល់អំណាចមេបាឲ្យទៅឈ្មោះ [redacted] វួចស៊ាង លើកូនទាំងបី ។

៣/ឲ្យឈ្មោះ [redacted] សុភាណ ផ្តល់អាហារកាតព្វកិច្ចដល់កូន ។

៤/បែងចែកទ្រព្យសម្បត្តិរួមដែលជាអចលនវត្ថុ "ផ្ទះ" ។ដោយសំអាងហេតុថា:ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាតាមប្រពៃណីតាំងពីឆ្នាំ១៩៨៨ប៉ុន្តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ឡើយ ។ រហូតមកដល់បច្ចុប្បន្នមានកូនចំនួន ៣នាក់ ។ កូនទី១ឈ្មោះ [redacted] សុភារ៉ា ភេទប្រុស អាយុ១៩ឆ្នាំ ,ទី២ឈ្មោះ [redacted] សៅរ៍មករា ភេទប្រុស អាយុ១៥ឆ្នាំ,ទី៣ឈ្មោះ [redacted] លាង ភេទស្រី អាយុ ៤ឆ្នាំ ។

ចាប់តាំងពីឆ្នាំ ២០០៤ មកឈ្មោះ [redacted] សុភាណ ចាប់ផ្តើមមានស្រីលួចលាក់ជាច្រើន ផឹកស្រារៀងរាល់ថ្ងៃ , វាយធ្វើបាបប្រពន្ធកូន និងជេរប្រមាថមើលងាយ គំរាមសម្លាប់មកលើរូបខ្លួនរហូតមានការប្តឹងទៅសាលាសង្កាត់ទួលស្វាយព្រៃទី៣និងធ្វើការសម្រុះសម្រួលជាច្រើនក៏ដោយមានផ្តិតមេដៃសន្យាថាបញ្ឈប់រាល់ការប្រើអំពើហឹង្សាមកលើរូបខ្លួន។តែឈ្មោះ [redacted] សុភាណ មិនបានគោរពទៅតាមការសម្រុះសម្រួលទេ គេនៅតែបន្តប្រើអំពើហឹង្សាមកលើរូបខ្លួន និងកូនប្រុសច្បងឈ្មោះ [redacted] សុភារ៉ា ដែលតែងតែឃាត់ឪពុកកុំឲ្យវាយធ្វើបាបខ្លួន ។ ថ្ងៃទី ១០ខែវិច្ឆិកា ឆ្នាំ២០០៩ ឈ្មោះ [redacted] សុភាណ បានបំផ្លិចបំផ្លាញទ្រព្យសម្បត្តិក្នុងផ្ទះបង្ករឿងក្នុងគ្រួសារ និងប្រើអំពើហឹង្សាធ្ងន់ធ្ងរ មកលើក្រុមគ្រួសារទាំងមូល ធ្វើឲ្យខ្ញុំដាក់ពាក្យប្តឹងសុំលែងលះ ទៅសាលាសង្កាត់ទឹកល្អក់៣ តែត្រូវបានសម្រុះសម្រួលផ្សះផ្សាជាថ្មីម្តងទៀត។ នៅចំពោះមុខគណ:កម្មាធិការដោះស្រាយទំនាស់ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ។ នៅក្នុងឆ្នាំដដែលឈ្មោះ [redacted] សុភាណ ក៏បានវាយដំយ៉ាងឃោរឃៅទៅលើកូនប្រុសច្បង ដោយបានយកកៅអីឈើប្រណិតមានទម្ងន់ធ្ងន់ មកវាយតម្រង់ក្បាលពេញមួយទំហឹង ប៉ុន្តែត្រូវបានប្អូនឈ្មោះ [redacted] វឌ្ឍន: ស្ទុះមកចាប់ទាន់ទើបឈ្មោះ [redacted] សុភារ៉ា មានឱកាសរត់គេចខ្លួន ធ្វើឲ្យឈ្មោះ [redacted] សុភាណ រឹតតែមានកំហឹងបន្ថែមទៀត។ នៅថ្ងៃទី ២៧ខែមេសា ឆ្នាំ២០១០ ឈ្មោះ [redacted] សុភាណ បន្តសកម្មភាពក្បត់ចិត្តរឹតតែធ្ងន់ធ្ងរ រហូតនាំស្រីកំណាន់ មកដេកក្នុង "បន្ទប់គេង ប្តី ប្រពន្ធ" នៅចំពោះមុខខ្លួនព្រមទាំងដើរផឹកស៊ីចាយលុយខ្ជះខ្ជាយមិនខ្វល់ពីស្ថានភាពគ្រួសារ ។ ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ដដែលឈ្មោះ [redacted] សុភាណ បានវាយខ្លួនចំមាត់បណ្តាល



Scanned with CamScanner

3/4

ឲ្យចេញឈាម និង បានបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ ដោយបានប្រមូលខោអាវទាំងខ្ញុំដុតចោល រីឯអាជ្ញាធរមូលដ្ឋានក៏ដូចជាមន្ត្រីនគរបាលបានត្រឹមតែធ្វើការសាកសួរកត់កំណត់ហេតុផ្សះផ្សា ពុំមានវិធានការសមស្រប ទៅតាមផ្លូវច្បាប់ឡើយ ។

**ការអះអាងរបស់ដើមចោទ**

-ដើមចោទឈ្មោះ [redacted] វ៉ូចស៊ាង នាពេលសវនាការ (អវត្តមាន)

**-មេធាវីដើមចោទ** [redacted] (អវត្តមាន)

**ការអះអាងរបស់ចុងចម្លើយ**

-ចុងចម្លើយឈ្មោះ [redacted] សុភាណ នាពេលសវនាការបានថ្លែងហេតុថាខ្ញុំបាទសុំទាមទារយកតូបមួយក្នុងចំណោមតូបទាំងពីរ គឺ តូបទី ១ លេខ ៣៦៦ នៅចំកាច់ជ្រុង-កែង-ខ្ញុំបាទប្រគល់ជូន ប៉ុន្តែចំពោះទី ២ លេខ ៣៥៦ នៅចំកណ្តាលខ្ញុំបាទសុំទាមទារគ្រប់គ្រង។ រីឯចំពោះអាហារកិច្ចដែលបានកំណត់ក្នុងសាលក្រមខ្ញុំបាទពុំទាន់មានលទ្ធភាពផ្តល់ទេ។ តែបើបានតូបនេះមកគ្រប់គ្រងខ្ញុំបាទសុំផ្តល់អាហារកិច្ចក្នុង ១ខែ ១០០$ (មួយរយដុល្លារអាមេរិក) តែបើថ្ងៃក្រោយខ្ញុំរកបាន -ធូរធារ- ខ្ញុំបាទ និងជួយផ្តល់ច្រើនជាងនេះទៀត ។

**សេចក្តីសន្និដ្ឋានរបស់មេធាវី**

-ចម្លើយដើមចោទ ឈ្មោះ[redacted]វ៉ូចស៊ាង នាពេលសវនាការ នៅសាលាដំបូង បានបញ្ជាក់ថាតូបរបស់គូភាគីមានពីរៈ ទី១ តូបលេខ ៣៦៦,ទី២ តូបលេខ ៣៥៦ ។ ក្នុងរឿងនេះភាគីខាងប្រពន្ធបានទាមទារយកទាំងពីរ ហើយបង្គាប់ឲ្យកូនក្តីខ្ញុំបាទបង់អាហារកិច្ចទៀត ។ ក្នុងបញ្ហានេះឃើញថា ពុំមានភាពយុត្តិធម៌សម្រាប់កូនក្តីខ្ញុំបាទឡើយ ។ ហើយម៉្យាងទៀតកូនក្តីខ្ញុំបាទក៏ពុំមានលទ្ធភាពផ្តល់អាហារកិច្ចទេ។ កូនក្តីខ្ញុំបាទគាត់សុខចិត្តប្រគល់តូបទី ១លេខ ៣៦៦ ប៉ុន្តែតូបលេខ ៣៥៦ កូនក្តីខ្ញុំបាទសុំទាមទារដើម្បីយកមករកស៊ីចិញ្ចឹមខ្លួន និងចិញ្ចឹមកូន ។

**សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ**

-ក្នុងរឿងវិវាទនេះលែងលះ គូភាគីពុំមានជំទាស់អ្វីទេ ។ ប៉ុន្តែមានការពាក់ពន្ធ័ទៅលើការបែងចែកទ្រព្យ -តូបនៅផ្សារ-គូភាគីបានបញ្ជាក់ច្បាស់ហើយថា ទ្រព្យដែលត្រូវចែកគ្នា គឺមានពីរតូបទី១ លេខ ៣៦៦នៅចំកែង-កាច់ជ្រុង-,និងតូបទី២ លេខ ៣៥៦នៅចំកណ្តាល ។

**សំអាងហេតុ**

១/បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២២/៨/២០១១ របស់លោក**មេធាវី** [redacted] តំណាងដោយអាណត្តិឲ្យឈ្មោះ [redacted] ប្តឹងឧទ្ធរណ៍ ត្រង់ចំណុចលេខ ២-ខ- និង ៣-គ- នៃសេចក្តីសំរេចនៃសាលក្រមរដ្ឋប្បវេណីលេខ ៣៣-ប-ចុះថ្ងៃទី ១០ខែ



Scanned with CamScanner

៨ ឆ្នាំ ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ធ្វើឡើងក្នុងកំណត់ច្បាប់យោង តាមមាត្រា លេខ ២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន ។

២/ពាក្យសុំពន្យាពេលចូលទាញហេតុផល ដោយផ្ទាល់មាត់ ចុះថ្ងៃទី ២១/០២/២០១២ របស់មេធាវី [redacted] តំណាងដោយអាណាត្តិ ឲ្យឈ្មោះ [redacted] វួចស៊ាង ដោយសំអាងថា កូនក្តីខ្លួនមានជំងឺរលាកក្រពះរើឡើង ធ្វើឲ្យសុខភាពទន់ខ្សោយ ត្រូវសំរាកព្យាបាលនៅមន្ទីរពេទ្យមួយរយៈដូចមានលិខិតបញ្ជាក់សុខភាពចុះថ្ងៃទី ២១/០២/២០១២ របស់មន្ទីរពេទ្យព្រះកុសមៈមិនគួរត្រូវបានអនុញ្ញាត្តិឲ្យពន្យាពេលទាញហេតុផលដោយផ្ទាល់មាត់ទេដោយហេតុថា បើទោះជា កូនក្តីខ្លួនឈ្មោះ [redacted] វួចស៊ាង មានជំងឺត្រូវព្យាបាលរយៈពេល ៥ថ្ងៃ ក៏ដោយ ក៏កូនក្តីលោកមេធាវីបានប្រគល់សិទ្ធិអំណាច តំណាងដោយអាណាត្តិ ឲ្យលោកមេធាវី មានសិទ្ធិអំណាចធ្វើសកម្មភាពនិងសម្រេចក្នុងនាមកូនក្តីបានដែរដូចមានក្នុងលិខិតប្រគល់សិទ្ធិចុះថ្ងៃទី ០៨/០២/២០១២ៗម្យ៉ាងទៀតលោកមេធាវីមានពេលវេលាគ្រប់គ្រាន់ក្នុងការសិក្សាសំណុំរឿងដោយបានថតចំលងសំណុំរឿងតាំងពីថ្ងៃទី ០៩/០២/២០១២ គឺមានរយៈពេល ១៣ថ្ងៃ ។ ម្យ៉ាងទៀតលោកស្រី [redacted] វួចស៊ាង បានទទួលដីកាកោះ តាំងពីថ្ងៃ ២៧/០១/២០១២ ហើយប្រគល់សិទ្ធិជូនលោកជាមេធាវីតំណាងដោយអាណាត្តិដល់ទៅពីររូបគឺលោកមេធាវី [redacted] និង មេធាវី [redacted] តាំងពីថ្ងៃទី ០៨/០២/២០១២ ដែលលោកមេធាវីទាំងពីរ អាចចូលរួមទាញហេតុផលផ្ទាល់មាត់ការពារផលប្រយោជន៍ឲ្យកូនក្តីលោកបាន ហើយលោកទាំងពីរ ក៏ពុំមានធុរៈចាំបាច់ណាមួយដែលអាចឲ្យក្រុមប្រឹក្សាពិចារណាសម្រេចពន្យាពេលការទាញហេតុផលផ្ទាល់មាត់តាមការស្នើសុំរបស់លោកមេធាវីទាំងពីរដែរ ។ ហេតុនេះដៀសវាង ការអូសបន្លាយនីតិវិធីដោយមិនសមហេតុផលដែលជាហេតុធ្វើឲ្យខាតប្រយោជន៍ដល់ភាគីម្ខាងទៀត ក្រុមប្រឹក្សាគប្បីដាក់សំណុំរឿងជំនុំជម្រះ ។

៣/តាមពាក្យបណ្តឹងរបស់ឈ្មោះ [redacted] វួចស៊ាង ចុះថ្ងៃទី ០១/០២/២០១១ បានបញ្ជាក់ថា ឈ្មោះ [redacted] សុភាព គ្មានមុខរបរ ឬការងារផ្ទាល់ខ្លួនទេ ដោយគ្រាន់តែជួយលក់ដូរខ្លួនបន្តិចតួច ។ ការអះអាងរបស់ដើមចោទនេះមានលក្ខណៈស្របគ្នា និងពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២២/៨/២០១១ ដែលថាឈ្មោះ [redacted] សុភាព សុំប្តឹងឧទ្ធរណ៍ត្រង់បង្គាប់ ឲ្យបង់ប្រាក់អាហារកិច្ចចិញ្ចឹមកូនក្នុង១ខែចំនួន ១.០០០.០០០៛ -មួយលានរៀល- ពីព្រោះឈ្មោះ [redacted] សុភាណ ពុំមានលទ្ធភាពបង់អាហារកិច្ច តាមការបង្គាប់នេះទេ ដោយសារតែឈ្មោះ [redacted] សុភាព ពុំមានការងារធ្វើ និងមិនទាន់រកប្រាក់ចំណូលបានដើម្បីចិញ្ចឹមជីវិតខ្លួនផងៗនាពេលទាញហេតុផលផ្ទាល់មាត់ឈ្មោះ [redacted] សុភាណ ក៏បានថ្លែងការណ៍ថា ខ្លួនគ្មានការងារ និងមុខរបរ រកស៊ីអ្វីទេ តាំងពីបែកបាក់គ្នាមកខ្លួនគ្មានលទ្ធភាពបង់ ១.០០០.០០០៛ ( មួយលានរៀល ) ទេ តែ

ខ្លួនសុំជួយចិញ្ចឹមកូនក្នុងមួយខែ ១០០$(មួយរយដុល្លារ)។ការថ្លែងការណ៍នេះមានលក្ខណៈសមស្របដែលភាគីដើមចោទ ក៏ទទួលស្គាល់ដែរថាឈ្មោះឈាង សុភាណ គ្មានមុខរបរឬការងារផ្ទាល់ខ្លួនទេ។ ហេតុនេះសាលាឧទ្ធរណ៍ គួរពិចារណា និងសម្រេចកែប្រែប្រាក់អាហារកិច្ចតាមលទ្ធភាពរបស់ភាគី ។

៣/តាមកំណត់ហេតុនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើទី ១កាលពីថ្ងៃទី០២ ខែ៣ ឆ្នាំ ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញគូភាគីទាំងពីរទទួលស្គាល់ថា សិទ្ធិជួលតូបលេខ ៣៥៦ និង ៣៦៦ អាគារ C₀ ជាទ្រព្យរួម ។ ដើមចោទ [redacted] វួចស៊ាង ក៏ទទួលស្គាល់នៅក្នុងពាក្យបណ្តឹងរបស់ខ្លួនចុះថ្ងៃទី ០១/០២/២០១១ថាឈ្មោះ [redacted] សុភាណ ក៏បានជួយលក់ដូរខ្លួនបន្តិចបន្តួចដែរ។ហេតុនេះឈ្មោះ [redacted] សុភាណ គប្បីទទួលបានចំណែកខ្លះពីសិទ្ធិជួលតូបទាំងពីរខាងលើដើម្បីអាចប្រកបរបររកស៊ីចិញ្ចឹមជីវិតខ្លួនឯងបាន និង អាចមានប្រាក់បង់អាហារកិច្ចចិញ្ចឹមកូនតាមការបង្គាប់របស់តុលាការបាន។ នាពេលទាញហេតុផលផ្ទាល់មាត់ឈ្មោះ [redacted] សុភាណ បានសុំទាមទារយកសិទ្ធិជួលតូបលេខ ៣៥៦C₀ ដែលតម្លៃតូបនេះមានតម្លៃប្រហែលជាង ១០ម៉ឺនដុល្លារអាមេរិកហើយខ្លួនសុខចិត្តប្រគល់សិទ្ធិជួលតូបលេខ ៣៦៦ C₀ ឲ្យដើមចោទ [redacted] វួចស៊ាង ដែលមានតម្លៃប្រហែលជាង ២០ម៉ឺនដុល្លារអាមេរិច ។

តាមលិខិតបញ្ជាក់ របស់ក្រុមហ៊ុន ថៃ ប៊ុនរ៉ុង ចុះថ្ងៃទី ១៤/៦/២០១១ តូបលេខ ៣៥៦ អាគាC₀ និងតូបលេខ ៣៦៦អាគាC₀ នេះមានរយៈពេលជួល ២០ឆ្នាំ។ តាមភស្តុតាង និងការថ្លែងការណ៍ របស់ភាគីខាងលើនេះ អាចបង្ហាញថា ការសុំទាមទារយកសិទ្ធិជួលតូប លេខ ៣៥៦អាគារ C₀ នៅផ្សារអូឡាំពិក មកកាន់កាប់ និងគ្រប់គ្រង ហើយសិទ្ធិជួលតូបលេខ ៣៦៦ អាគារ C₀ សុខចិត្តប្រគល់ឲ្យដើមចោទនោះ មានលក្ខណៈសមហេតុផល ដែលអាចឲ្យសាលាឧទ្ធរណ៍សម្រេចតាមការស្នើសុំព្រោះសិទ្ធិជួលតូបនេះ ជាទ្រព្យរួម គប្បីយកមកចែកគ្នារវាងគូភាគី ហើយម្យ៉ាង ដើម្បីឲ្យចុងចម្លើយឈ្មោះ [redacted] សុភាណ មានមុខរបររកស៊ីចិញ្ចឹមជីវិតបន្ត បន្ទាប់ពីបែកបាក់ជាស្ថាពរ ។

៤/ចំណុចទី ២"ខ" និង ៣"គ" នៃសេចក្តីសម្រេច នៃសាលក្រមរដ្ឋប្បវេណីលេខ ៣៣ "ប" ចុះថ្ងៃទី ១០/៨/២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ មានលក្ខណៈខុសឆ្គង គប្បីសាលាឧទ្ធរណ៍ធ្វើការកែប្រែតាមការយល់ឃើញខាងលើ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១/ទទួលស្គាល់បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២២/៨/២០១១ របស់លោក [redacted] តំណាងដោយអាណត្តិឲ្យឈ្មោះ [redacted] សុភាណ ត្រង់ចំណុចទី ២"ខ" និង ៣"គ" នៃសេចក្តីនៃសាលក្រមរដ្ឋប្បវេណីលេខ ៣៣"ប"ចុះថ្ងៃទី ១០/៨/២០១១ ។

៣៣០៧៦០

Scanned with CamScanner

២/តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ៣៣ "ប" ចុះថ្ងៃទី ១០/៨/២០១១ទុកជាបានការ ដោយគ្រាន់តែកែប្រែចំណុចទី ២ "ខ" ពីការ "បង្គាប់ឲ្យឈ្មោះ [redacted] សុភាណ បង់អាហារកិច្ចចិញ្ចឹមកូនទាំងពីរនាក់ក្នុងមួយខែចំនួន ១.០០០.០០០៛(មួយលានរៀល)" មកជា "បង្គាប់ឲ្យឈ្មោះ [redacted] សុភាណ បង់អាហារកិច្ចចិញ្ចឹមកូនទាំងពីរនាក់ក្នុងមួយខែ ៤០០.០០០៛ ទៅឲ្យឈ្មោះ [redacted] វួចស៊ាង" និងកែប្រែចំណុចទី ៣"គ" ពីការ "ប្រគល់សិទ្ធិជួលតូបលេខ ៣៥៦ និងលេខ ៣៦៦ អាគារ $C_0$ ក្នុងមជ្ឈមណ្ឌលពាណិជ្ជកម្មអូឡាំពិកឲ្យទៅដើមចោទឈ្មោះ [redacted] វួចស៊ាង" មកជា "ប្រគល់សិទ្ធិជួលតូបលេខ៣៥៦អាគារ $C_0$ ក្នុងមជ្ឈមណ្ឌលពាណិជ្ជកម្មអូឡាំពិកឲ្យទៅចុងចម្លើយឈ្មោះ [redacted] សុភាណ និង ប្រគល់សិទ្ធិជួលតូបលេខ ៣៦៦ អាគារ $C_0$ ក្នុងមជ្ឈមណ្ឌលពាណិជ្ជកម្មអូឡាំពិកឲ្យទៅដើមចោទឈ្មោះ [redacted] វួចស៊ាង"។ចំណុចក្រៅពីនេះរក្សាទុកជាបានការដដែល ។

៣/ប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ជាបន្ទុករបស់ដើមចោទឈ្មោះ [redacted] វួចស៊ាង ។

សាលដីកានេះទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២២/០២/២០១២។ បើកសិទ្ធិប្ដឹងសាទុក្ខក្នុងរយៈពេល ១ខែ គិតថ្ងៃទទួលការបញ្ជូនសាលដីការនេះ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |

[redacted]

| បានឃើញ | បានចម្លងត្រឹមត្រូវតាមច្បាប់ដើម |
|---|---|
| ប្រធានក្រុមប្រឹក្សាជំនុំជំរះ | សាលាឧទ្ធរណ៍ថ្ងៃទី... ខែកុម្ភៈ ឆ្នាំ ២០១២ |
| [redacted] | ក្រឡាបញ្ជីលិខិតនានា |
| | [redacted] |